**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
Ministry of Industry & Handicraft
លេខ : ៥៤៩ ឧស....

រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៥

# សេចក្តីជូនដំណឹង

អនុវត្តតាមចំណាររបស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ចុះថ្ងៃទី ២៦ ខែមីនា ឆ្នាំ២០១៥ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានកិត្តិយសជម្រាបជូនបណ្តាក្រុមហ៊ុន សហគ្រាស ឬ បុគ្គលទាំអស់ឲ្យបាន ជ្រាបថា តាមរយៈហិរញ្ញប្បទានរបស់ធនាគារពិភពលោក អតីតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បានសាងសង់រោងចក្រ ផលិតទឹកស្អាត នៅក្នុងឃុំកំពង់ចក ស្រុករំដួល និងឃុំកណ្តៀងរាយ ស្រុកស្វាយទាប ខេត្តស្វាយរៀង ក្រោមរូបភាពគម្រោង DBL (Design Build and Lease)។ ក្រុមហ៊ុន CCEC ដែលជាក្រុមហ៊ុនបានចុះកិច្ចសន្យាជាមួយអតីតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការជួលទីតាំងរោងចក្រផលិតទឹកស្អាត ដើម្បីដំណើរការផលិត និងចែកចាយទឹកស្អាត នៅក្នុងឃុំទាំងពីរនេះ ដោយមូលហេតុមិនមានសមត្ថភាពបច្ចេកទេស និងបញ្ហាប្រភពទឹក បានស្នើសុំមកក្រសួងដើម្បីបញ្ចប់កិច្ចសន្យា។

ដោយយោងតាមតម្រូវការចាំបាច់ក្នុងការបន្តការផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋ នៅក្នុងភូមិសាស្ត្រទាំងពីរឃុំខាងលើនេះ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន សហគ្រាស ឬ បុគ្គលទាំអស់ ដែលមានចំណាប់អារម្មណ៍ មកចូលរួមដាក់ឯកសារស្នើជួលរោងចក្រផលិតទឹកស្អាត ដើម្បីផលិត និងចែកចាយទឹកស្អាត នៅទីតាំងទាំងពីរឃុំខាងលើនេះ។ លក្ខខណ្ឌនៃការជួលមានដូចខាងក្រោម៖

- ត្រូវធានានិរន្តភាពនៃការផ្គត់ផ្គង់ទឹកស្អាត ដែលមានគុណភាព និងសុវត្ថិភាព ជូនប្រជាពលរដ្ឋ
- ត្រូវថែទាំ និងជួសជុលមធ្យោបាយផលិតកម្ម និងប្រព័ន្ធចែកចាយ ធានាឲ្យបាននូវប្រសិទ្ធិភាពនៃដំណើរការផលិត និងចែកចាយទឹកស្អាត របស់ប្រព័ន្ធ
- ត្រូវបន្តពង្រីកផ្ទៃសេវា ដើម្បីគ្របដណ្តប់ឲ្យបាន ១០០% នៅក្នុងរយៈពេល ០៣ ឆ្នាំ គិតពីថ្ងៃចុះកិច្ចសន្យា
- ត្រូវអនុវត្តគោលនយោបាយនានា ដើម្បីគាំទ្រដល់អតិថិជនក្រីក្រ ដូចជាបង់រំលស់ថ្លៃតបណ្តាញចូលផ្ទះជាដើម
- ត្រូវបង់ថ្លៃឈ្នួលប្រចាំខែជូនក្រសួងឧស្សាហកម្ម និងសិប្បកម្ម (ស្នើឡើងដោយអ្នកចូលរួមដាក់ឯកសារស្នើ)

ក្រុមហ៊ុន សហគ្រាស ឬ បុគ្គល ដែលមានចំណាប់អារម្មណ៍ សូមអញ្ជើញទាក់ទង និងសាកសួរព័ត៌មានលម្អិត នៅ នាយកដ្ឋានទឹកស្អាត នៃក្រសួងឧស្សាកម្ម និងសិប្បកម្ម ដែលមានអាស័យដ្ឋានដូចខាងក្រោម ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ នៅរៀងរាល់ថ្ងៃធ្វើការ ចាប់ពី **ម៉ោង ០៨:៣០ ព្រឹក ដល់ម៉ោង ០៥:០០ រសៀល**។

ក្រសួងនឹងរៀបចំកិច្ចប្រជុំបើកឯកសារស្នើនៅថ្ងៃទី ***២០ ខែមេសា ឆ្នាំ២០១៥ វេលាម៉ោង ៨:០០ ព្រឹកគត់*** នៅបន្ទប់ប្រជុំរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ឯកសារស្នើ ត្រូវដាក់ជូនក្រសួង មិនឲ្យយឺតជាងពេលបើកឯកសារស្នើខាងលើ ជាដាច់ខាត និងត្រូវភ្ជាប់មកជាមួយនូវប្រាក់កក់ធានានៃការស្នើ ចំនួន **៥០០០ ដុល្លារអាមេរិក** សម្រាប់ ១ ទីតាំង។ ប្រាក់កក់ធានា អាចជាសាច់ប្រាក់ មូលប្បទានបត្រ ឬ លិខិតធានារបស់ធនាគារដែលក្រសួងទទួលស្គាល់។ ប្រាក់កក់នឹងប្រគល់ជូនអ្នកស្នើវិញនៅពេលមានការព្រមព្រៀងអនុវត្តកិច្ចសន្យា ឬ ត្រូវរឹបអូស ក្នុងករណីដែលអ្នកស្នើបដិសេធអនុវត្តតាមការស្នើរបស់ខ្លួន។

**ជ. រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ**

**ឯក សុនចាន់**

**អាស័យដ្ឋានទំនាក់ទំនង៖**
នាយកដ្ឋានទឹកស្អាត ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
#៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ
លោក តាន់ សុវិទ្យា ប្រធាននាយកដ្ឋានទឹកស្អាត
០១២ ៩៨៧ ៨៥១ ឬអ៊ីម៉េល tansoviddhya@yahoo.com